រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

052KH01A-01

ចូរយើងធ្វើអោយក្រុមជំនុំរីកចំរើនឡើង



កូនស្បៀរភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៥២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

១- ឧបសគ្គដែលរារាំងមិនឱ្យក្រុមជំនុំអ្នកអាចរីកចំរើនបាន

- ការប្រកាសដំណឹងល្អមិនច្បាស់លាស់ប្រាប់អ្នកដទៃ ។
- ការបង្ខំមនុស្សអោយក្លាយជាគ្រីស្តជនមុនកំណត់ ។
- ការប្រើមធ្យោបាយបំភាន់ភ្នែក ដើម្បីទាក់ទាញមនុស្ស អោយក្លាយជាគ្រីស្តជន ។
- ការប្រកាសដំណឹងល្អដោយធ្វើបូកពារដួចជនបរទេស ។
- គ្រួគង្វាលធ្វើការងារគ្រប់យ៉ាង ដោយខ្លួនឯង ។

ថ្ងៃនេះ មានភ្ញៀវមកព្រះវិហារច្រើនណាស់ ព្រោះពីអាទិត្យមុន លោកគ្រូជុនបានប្រាប់ក្រុមជំនុំ អោយនាំមិត្តភក្តិមកស្តាប់សេចក្តីអធិប្បាយមួយអំពីការសង្គ្រោះ ។ ពួកអ្នកទាំងនោះមិនដែលឮដំណឹងល្អអំពីព្រះយេស៊ូទាល់តែសោះ ។ លោកគ្រូជុនអធិប្បាយអំពីពួកយូដា នៅពេលដែលពួកគេធ្វើជាទាសករ នៅក្នុងប្រទេសអេស៊ីប :

- ក្រៅពីផ្សាយដំណឹងល្អប្រាប់សាច់ញាតិ និង មិត្តភក្តិ សមាជិកក្រុមផ្សាយដំណឹងល្អប្រាប់មនុស្ស ដែលមិនទាន់ឮពីដំណឹងល្អរបស់ព្រះយេស៊ូ ។
- រៀបចំក្រុមបង្កើតសាវ័កតាមផ្ទះ ដើម្បីបង្រៀនពួកអ្នកជឿថ្មី ។

៤- បង្ហាត់បង្រៀនអ្នកដឹកនាំក្រុមតួច ដើម្បីអោយពួកគេអាចបង្រៀនអ្នកឯទៀត នៅក្នុងក្រុមតួចអោយ :

- ប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ។
- អធិស្ឋានសំរាប់គ្រួសារ និង អ្នកជិតខាង ។
- ទៅសួរសុខទុក្ខ និង ផ្សាយដំណឹង ល្អប្រាប់សាច់ញាតិ មិត្តភក្តិ និង អ្នកជិតខាង ។

៥- សរសេរឈ្មោះពួកអ្នកដឹកនាំក្រុមតួច និង ក្រុមរបស់ពួកគេរៀងៗខ្លួន ។

អ្នកដឹកនាំ : **ក្រុម :**

_____ _____

_____ _____

_____ _____

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

១- អធិស្ឋានទូលសូមឱ្យព្រះជាម្ចាស់ដឹកនាំអ្នក ក្នុងការណែនាំប្រមូលក្រុមជំនុំអ្នក និង បង្ហាត់បង្រៀនពួកគេអោយផ្សាយដំណឹងល្អ និង បង្កើតសាវ័ក ។

២- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ប្រើក្រុមជំនុំអ្នក និង ក្រុមជំនុំឯទៀត ឱ្យចែកចាយដំណឹងល្អនៅទីកន្លែង ដែលមិនទាន់មានក្រុមជំនុំនៅឡើយ ។

៣- រៀបចំក្រុមជំនុំរបស់អ្នក អោយផ្សាយដំណឹងល្អ និង បង្កើតសាវ័កដោយអនុវត្តវិធីមួយ ដែលមានប្រសិទ្ធិភាព ។

អ្នកអាចប្រើវិធី ដែលមានដាក់ជូននៅក្នុងកូនសៀវភៅនេះ :

- បណ្តុះបណ្តាលពួកអ្នកជឿអោយមានសមត្ថភាព អាចបំពេីកិច្ចការ ជាអ្នកដឹកនាំក្រុមផ្សាយដំណឹងល្អ ។
- រៀបចំក្រុមផ្សាយដំណឹងល្អ សំរាប់សហគមន៍ផ្សេងៗគ្នា ។
- សមាជិកក្រុមចាប់ផ្តើម ដោយផ្សាយដំណឹងល្អប្រាប់សាច់ញាតិ និង មិត្តភក្តិរបស់ពួកគេ ។

ជនជាតិយូដា ដែលជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ បានជាប់ជាទាសករ នៅក្នុងប្រទេសអេស៊ីប អស់រយៈពេល ៤០០ ឆ្នាំ ! ។



តើជនជាតិយូដាជាអ្នកណា ? ព្រះជាម្ចាស់ជាព្រះកាចណាស់ អញ្ចឹង បានជាទុកអោយរាស្ត្ររបស់ព្រះអង្គធ្វើជាទាសកររយៈយ៉ាងនេះ ! ។



ក្រោយការអធិប្បាយ :



ថ្ងៃអាទិត្យបន្ទាប់ នៅក្នុងក្រុមជំនុំរបស់លោកគ្រូជុន :



តើអ្នកនឹងបង្ហាត់បង្រៀនអ្នកដឹកនាំក្រុមទាំងនេះ ដោយរបៀបណា ? ។

© Project WorldReach © SEAN

តើក្រុមជំនុំអ្នកត្រូវការរៀបចំឡើងវិញដូចនេះទេ ដើម្បីឱ្យអាចរីកចំរើនបាន ? ។

តើអ្នកមានផែនការអ្វី ដើម្បីរៀបចំក្រុមថ្មីៗ ? ។

តើក្រុមថ្មីទាំងនោះនឹងធ្វើអ្វីខ្លះ ? ។



© Project WorldReach © SEAN

នៅផ្ទះរបស់លោកគ្រូឆាយ :



យោងទៅតាម ខ ១១ តើព្រះជាម្ចាស់ប្រទានតួនាទីអ្វីខ្លះដល់ក្រុមជំនុំ ? ។

_____

_____

៦- បើសេចក្តីខាងក្រោមនេះត្រូវ សូមសរសេរអក្សរ « ត » ក្បែរ តែបើខុស សូមសរសេរអក្សរ « ខ » ។

ការស្តាប់បង្គាប់ (ភាពវិសុទ្ធ) និង ការផ្សាយដំណឹងល្អត្រូវតែមានព្រមគ្នា ។ _____

៧- សូមអាន សេរីភាព ១៨:១៣-២៧ រួចឆ្លើយសំនួរខាងក្រោមនេះ :

តើលោកម៉ូសេធ្វើដូចម្តេច ដើម្បីឃ្វាលមនុស្សអោយមានប្រសិទ្ធិភាព ? ។

_____

_____

_____

_____

៥- សូមអាន អេភេសូ ៤:១១-១៦ ហើយឆ្លើយសំនួរខាងក្រោមនេះ :

យោងទៅតាម ខ ១២ តើគ្រូគង្វាល និង ពួកអ្នកដឹកនាំក្រុមជំនុំ មានភារៈកិច្ចដូចម្តេច ? ។

_____

_____

_____

យោងទៅតាម ខ ១៣-១៦ តើការកសាងក្រុមជំនុំរបស់ព្រះគ្រីស្ត មានគោលដៅដូចម្តេច ? ។

_____

_____

_____

_____

_____

_____

_____

មួយខែក្រោយមក :



ពីអាទិត្យមុន ខ្ញុំបានឮគេនិយាយអំពីក្រុមជំនុំ ដែលចែកអង្ករជូនអ្នកដែលមកព្រះវិហារពួកគេ ជាលើកទីមួយ ។ បើសិនជាខ្ញុំចែកអង្ករជូនភ្ញៀវ ដែលមកព្រះវិហារខ្ញុំជាលើកទីមួយដែរ ប្រហែលជាក្រុមជំនុំរបស់ខ្ញុំនឹងរីកចំរើនយ៉ាងឆាប់រហ័សហើយ ! ។

លោកគ្រូជុនបានចាប់ផ្តើមចែកអង្ករជូនភ្ញៀវទាំងអស់ នៅថ្ងៃអាទិត្យទីមួយនៃខែឧសភា ។ នៅថ្ងៃអាទិត្យទីពីរនៃខែឧសភា មានភ្ញៀវដប់នាក់ទៀតមកព្រះវិហារ ។ លោកគ្រូត្រូវបង្ខំចិត្តចែកអង្ករជូនអ្នកថ្មីទាំងដប់នាក់នោះដែរ ។ នៅថ្ងៃអាទិត្យទីបីមានភ្ញៀវម្ភៃនាក់ទៀតមកព្រះវិហារ ។ លោកគ្រូជុនជូនអង្ករទៅអ្នកថ្មីទាំងម្ភៃនាក់នោះទៀតដែរ ។

ប៉ុន្តែ នៅពេលនោះ គាត់ចាយប្រាក់មូលនិធិរបស់ក្រុមជំនុំអស់ ។ នៅថ្ងៃអាទិត្យទីបួន គាត់ប្រកាសថា គាត់មិនអាចចែកអង្ករជូនអ្នកមកថ្មីជាទៀងទាត់ទេ ។ នៅថ្ងៃអាទិត្យទីមួយនៃខែមិថុនា គ្មានភ្ញៀវមកព្រះវិហារសោះ ។



លោកគ្រូជុនអធិស្ឋានទៅព្រះជាម្ចាស់ថា÷



៤- សូមគូរសញ្ញាសំគាល់វិធីផ្សាយដំណឹងល្អ ដែលមានប្រសិទ្ធិភាពជាងគេ ។

- ☐ គ្រូគង្វាលទទួលខុសត្រូវលើការផ្សាយដំណឹងល្អទាំងអស់ ។
- ☐ រៀបចំធ្វើតែកម្មវិធីផ្សាយដំណឹងល្អពិសេសៗ នៅក្នុងក្រុមជំនុំ ។
- ☐ អញ្ជើញគ្រីស្តជនរបស់ក្រុមជំនុំផ្សេងទៀត អោយមកចូលរួមជាមួយក្រុមជំនុំអ្នក ។
- ☐ បង្ហាត់បង្រៀន និង ណែនាំសមាជិកទាំងអស់របស់ក្រុមជំនុំ អោយផ្សាយដំណឹងល្អប្រាប់មនុស្សឯទៀត ជាទៀងទាត់ ដោយបង្កើតក្រុមផ្សាយដំណឹងល្អ ។
- ☐ ចែកចាយដំណឹងល្អតាមរយៈមេគ្រួសារ នៅពេលដែលអាចធ្វើបាន ។
- ☐ ដឹកនាំក្រុមគ្រួសារទាំងមូលៗ អោយមានជំនឿលើព្រះយេស៊ូ ។

ការពិនិត្យមើលឡើងវិញ

១- តើយើងត្រូវកសាងក្រុមជំនុំលើគ្រឹះអ្វី ? ។ _____

២- សរសេរខុបសគ្គប្រាំយ៉ាង ដែលរារាំងមិនអោយក្រុមជំនុំរីកចំរើន ។

_____

_____

_____

_____

_____

៣- តើសេចក្តីបង្គាប់សំខាន់ៗទាំងប្រាំពីររបស់ព្រះយេស៊ូ ដែលអ្នកត្រូវបង្រៀនពួកអ្នកជឿថ្មីទាំងអស់ មានអ្វីខ្លះ ? ។

_____

_____

_____

_____

ព្រះវិញ្ញាណដ៏វិសុទ្ធបណ្តាលចិត្តគាត់អោយអាន ១ កូរិនថូស ៣:១០-១៤ ដែលចែងអំពីការសាងសង់លើគ្រឹះត្រឹមត្រូវ ។

លោកគ្រូជុនក៏កែប្រែចិត្តគំនិតថា៖

ឱព្រះជាម្ចាស់អើយ ! កូនមិនបានវិតវំកសាងក្រុមជំនុំរបស់កូនលើគ្រឹះរបស់ព្រះយេស៊ូគ្រីស្តទេ តែកូនបែរទៅជាកសាងក្រុមជំនុំ ដោយសារអង្ករទៅវិញ ។ មនុស្សមកព្រះវិហារ ដើម្បីឱ្យបានអាហារសំរាប់ចំអែតក្រពះរបស់គេប៉ុណ្ណោះ គឺមិនមែនមកដើម្បីឱ្យបានអាហារសំរាប់ព្រលឹងរបស់ពួកគេទេ ហើយកូនបានឃើញថា អ្នកមានជាច្រើនក៏មកព្រះវិហារ ដើម្បីទទួលអំណោយអង្ករ ដោយឥតគិតថ្លៃនេះដែរ ។ ប៉ុន្តែ ពេលដែលលែងមានការចែកអង្ករ មនុស្សក៏លែងមកដែរ ព្រោះការចែកអង្ករ គ្រាន់តែជាមធ្យោបាយបំភាន់ភ្នែកសំរាប់ទាក់ទាញមនុស្សប៉ុណ្ណោះ ។ សូមព្រះអង្គជួយកូនឱ្យចេះទុកចិត្តលើព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីអាចដឹកនាំមនុស្សមកថ្វាយព្រះអង្គ ដោយផ្សាយដំណឹងល្អប្រាប់គេ ។ ថ្ងៃស្អែក កូននឹងទៅសួរសុខទុក្ខមនុស្សតាមផ្ទះ ដើម្បីចែកចាយដំណឹងល្អប្រាប់គេផ្ទាល់មួយទល់នឹងមួយ ។



ស្អែកឡើង ...



ជំនុំតាមផ្ទះ ។ មិនមែនអ្នកជឿថ្មីទាំងអស់ ត្រូវតែទៅក្រុមជំនុំធំ (ម្តាយ) ជាចាំបាច់ទេ ។ ក្រុមជំនុំតាមផ្ទះអាចបង្កើតក្រុមជំនុំតាមផ្ទះផ្សេងៗទៀត ដោយស្រួលនៅក្នុងតំបន់ក្បែរៗគ្នានោះ ដែលនាំឱ្យអាចបង្កើនចំនួនពួកអ្នកជឿ ដែលដើរតាមព្រះគ្រីស្ត បានយ៉ាងឆាប់រហ័ស ។

បើសិនជាមានក្រុមតូចជាច្រើនជួបជុំគ្នាទៀងទាត់ ប្រហែលជាអាចអោយក្រុមតូចទាំងអស់នោះជួបជុំជាមួយគ្នា ជាក្រុមធំមួយមួយខែម្តង ឬ ជាងមួយខែម្តង ។

បើគ្រូគង្វាលបង្ហាត់បង្រៀនមនុស្សកាន់តែច្រើន អោយចេះដឹកនាំក្រុមតូចផ្សេងៗ ដែលមានតួនាទីផ្សេងៗគ្នា នោះក្រុមជំនុំនឹងរីកចំរើនកាន់តែខ្លាំង ទាំងខាងចំនួន ទាំងខាងព្រលឹងវិញ្ញាណ ។ ក្រៅពីក្រុមផ្សាយដំណឹងល្អ គ្រូគង្វាលអាចរៀបចំពួកអ្នកដឹកនាំ និង ក្រុមផ្សេងទៀត ដែលនឹងជួយបំពេញកិច្ចការឃ្វាល ។ បើមានមនុស្សស្ម័គ្រចិត្តចូលរួមជួយបំពេញមុខងារបំរើរបស់ក្រុមជំនុំកាន់តែច្រើន ក្រុមជំនុំនឹងកាន់តែបំរើព្រះជាម្ចាស់ និង មនុស្សឯទៀត ប្រកបដោយប្រសិទ្ធិភាព ។

© Project WorldReach © SEAN

រៀបចំក្រុមបង្កើតសាវ័កតាមផ្ទះ ដើម្បីបង្រៀនពួកអ្នកជឿថ្មី

បើសិនជានៅក្នុងសហគមន៍មួយមានគ្រួសារចំនួនបី ឬ លើសពីបី ទទួលដំណឹងល្អរបស់ព្រះយេស៊ូ សូមរៀបចំអោយគ្រួសារទាំងនោះមានឱកាសអាចទទួលទានអាហារជុំជាមួយគ្នា ឬ អាចធ្វើសកម្ម-ភាពពិសេសមួយរួមជាមួយគ្នា ។

ក្រោយពីដឹកនាំពួកគេអោយទាក់ទងស្គាល់គ្នាហើយ សូមប្រមូលគ្រួសារទាំងនោះជាក្រុមតូចមួយ ក្នុងគោលដៅបង្កើតសាវ័ក ។ ការជួបជុំគ្នាទៀងទាត់តាមផ្ទះដូចនេះ ធ្វើឱ្យអ្នកចូលរួមមានឱកាសសិក្សាព្រះគម្ពីរ អធិស្ឋាន និង ថ្វាយបង្គំរួមជាមួយគ្នា ។ នៅក្នុងដំណាក់ការនេះ សូមបង្រៀនពួកអ្នកជឿអោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត អធិស្ឋានសំរាប់ក្រុមគ្រួសារ ព្រមទាំងអ្នកជិតខាង ហើយផ្សាយដំណឹងល្អប្រាប់សាច់ញាតិ និង មិត្ត-ភក្តិ និង អ្នកជិតខាងរបស់ពួកគេ ។

ដំបូង អ្នកដឹកនាំក្រុមផ្សាយដំណឹងល្អត្រូវដឹកនាំការប្រជុំ ដើម្បីបង្កើតសាវ័កនេះ ។ ប៉ុន្តែ អ្នកដឹកនាំអាចបង្ហាត់បង្រៀនមនុស្សម្នាក់ដែលនៅក្នុងក្រុមតូចអោយក្លាយជាអ្នកដឹកនាំ ឬ គ្រូគង្វាលរបស់ក្រុមនោះ ។ នៅពេលក្រោយមក ក្រុមនេះអាចក្លាយជាក្រុម

លោកគ្រូជុនធ្លាក់ទឹកចិត្តណាស់ គាត់ក៏ទៅសុំសួរយោបល់ពីលោកគ្រូឆាយម្តងទៀត :





ក្រៅពីផ្សាយដំណឹងល្អត្រាប់សាច់ញាតិ និង មិត្តភក្តិ សមាជិកក្រុមត្រូវផ្សាយដំណឹងល្អត្រាប់មនុស្ស ដែលមិនទាន់ឮពីដំណឹងល្អរបស់ព្រះយេស៊ូ

នៅពេលដែលសមាជិកក្រុមបានទៅសួរសុខទុក្ខសាច់ញាតិ និង មិត្តភក្តិរបស់ពួកគេមួយចំនួនធំហើយ សូមអោយពួកគេបន្តផ្សាយដំណឹងល្អ ដោយទៅសួរសុខទុក្ខ និង ចែកចាយដំណឹងល្អរបស់ព្រះយេស៊ូត្រាប់អ្នកឯទៀត ដែលនៅក្នុងសហគមន៍ ។

គ្រីស្តជនខ្លះមិនចូលចិត្តទាក់ទងជាមួយអ្នកមិនទាន់ជឿទេ ព្រោះពួកគេគិតថា ខ្លួនគេវិសុទ្ធមិនហ៊ានទាក់ទងជាមួយមនុស្សមានបាបទេ ។ ពួកគណៈផារីស៊ីបានចោទប្រកាន់ព្រះយេស៊ូថា ព្រះអង្គទាក់ទងជាមួយមនុស្សមានបាប ។ តើមនុស្សឯទៀតអាចស្គាល់ព្រះយេស៊ូ ដោយរបៀបណាទៅ បើយើងមិនរាប់គេជាមិត្តនោះ ? ព្រះយេស៊ូយាងមកដើម្បីស្វែងរក និង សង្គ្រោះមនុស្ស ដែលបាត់បង់ ។ ហេតុនេះហើយ បានជាព្រះអង្គសោយអាហារ និង ជជែកជាមួយមនុស្សមានបាប ។ ព្រះអង្គមិនមែនចូលរួមប្រព្រឹត្តអំពើបាបជាមួយពួកគេទេ តែព្រះអង្គធ្វើជាគំរូអំពីសេចក្តីស្រឡាញ់ និង សេចក្តីសុចរិតដល់ពួកគេប៉ុណ្ណោះ ។ ចុះអ្នកវិញ ? ។

© Project WorldReach © SEAN

សមាជិកក្រុមចាប់ផ្តើម ដោយផ្សាយដំណឹងល្អប្រាប់ សាច់ញាតិ និង មិត្តភក្តិរបស់ពួកគេ

ក្រុមផ្សាយដំណឹងល្អ ត្រូវចាប់ផ្តើមដោយចេញទៅពីរៗនាក់ ទៅសួរសុខទុក្ខសាច់ញាតិ និង មិត្តភក្តិរបស់ពួកគេ ។ នៅពេលទៅសួរសុខទុក្ខ សមាជិកក្រុមត្រូវធ្វើសកម្មភាពខាងក្រោមនេះខ្លះ :

- ចូលរួមជជែកលេងជាមួយគ្រួសារ ជាពិសេស មេគ្រួសារ ។
- ជួយដោះស្រាយសេចក្តីត្រូវការរបស់គ្រួសារ (ដូចជាបង្រៀនពួកគេអោយចេះអាន ឬ អោយចេះជួសជុលកង់ ឬ អោយចេះបង្ការជំងឺ ។ល។) ។
- ចែកចាយអំពីជំនឿរបស់អ្នកផ្ទាល់លើព្រះយេស៊ូ ។
- អធិស្ឋានអោយអ្នកជំងឺ និង អ្នកដែលមានបញ្ហា ។
- ចែកចាយដំណឹងល្អ ដោយនិទានរឿង ។
- បង្រៀនមេរៀនអំពីសៀវភៅដំណឹងល្អ ។
- បង្ហាញចរិតលក្ខណៈ ដែលពេញដោយសេចក្តីមេត្តាករុណា សេចក្តីស្រឡាញ់ និង ភាពវិសុទ្ធ ។

ហេតុអ្វីបានជាក្រុមជំនុំលោកគ្រូជុនមិនរីកចំរើន ? ។

តើមនុស្សក្នុងប្រទេសអ្នក កសាងក្រុមជំនុំលើគ្រឹះខុសឆ្គងអ្វីខ្លះ ? (១ កូរិនថូស ៣:១០-១៤) ។

តើអ្នកអាចជួយក្រុមជំនុំរបស់ព្រះយេស៊ូគ្រីស្តអោយរីកចំរើនឡើងបាន តាមរបៀបអ្វីខ្លះ ? (រ៉ូម ១០:១៣-១៥) ។

© Project WorldReach © SEAN

២- មធ្យោបាយសំរាប់ជួយក្រុមជំនុំរបស់អ្នកឱ្យរីកចំរើនឡើង

- បង្រៀនពួកអ្នកជឿថ្មី នៅក្នុងក្រុមជំនុំរបស់អ្នកឱ្យចេះប្រតិបត្តិតាមព្រះគ្រីស្ត ។
- រៀបចំពួកអ្នកជឿស្មោះត្រង់ អោយចេះទៅសួរសុខទុក្ខ និង ផ្សាយដំណឹងល្អដល់មេគ្រួសារ និង គ្រួសារទាំងមូលៗ ។

លោកគ្រូជុនត្រូវការអោយអ្នកផ្តល់យោបល់អោយគាត់ ។ សូមស្តាប់គំនិតខុសឆ្គងរបស់គាត់ :



នៅពេលបង្ហាត់បង្រៀនក្រុមផ្សាយដំណឹងល្អ ពួកអ្នកដឹកនាំត្រូវជួបប្រជុំជាមួយគ្រូគង្វាល និង ពួកអ្នកដឹកនាំឯទៀត ប្រហែលជាមួយខែម្តង ដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមក វាយតំលៃការងារផ្សាយដំណឹងល្អរបស់ពួកគេ រៀបចំផែនការ និង ដោះស្រាយបញ្ហា ។

កូនសៀវភៅបង្ហាត់បង្រៀនគ្រូគង្វាល ទី ២ - «របៀបផ្សាយដំណឹងល្អ »ដោយប្រើមេរៀនដំណឹងល្អ ជាសំភារៈមានប្រយោជន៍សំរាប់បង្ហាត់បង្រៀនពួកអ្នកផ្សាយដំណឹងល្អ ។



ពួកគេប៉ុណ្ណោះ តែត្រូវនាំពួកគេឱ្យចេញទៅស្តារសុខទុក្ខ ពួកអ្នក
មិនទាន់ជឿផងដែរ ។ សូមធ្វើជាគំរូបង្ហាញពួកគេ អំពីការបង្កើត
ទំនាក់ទំនង និង ការចែកចាយដំណឹងល្អប្រាប់មេគ្រួសារ និង ក្រុម
គ្រួសារទាំងមូល ។

រៀបចំក្រុមផ្សាយដំណឹងល្អសំរាប់សហគមន៍ផ្សេងៗគ្នា

គ្រូគង្វាល និង អ្នកដឹកនាំក្រុមតូចផ្សាយដំណឹងល្អ រៀបចំក្រុម
ផ្សាយដំណឹងល្អ ដែលត្រូវនៅក្រោមការទទួលខុសត្រូវរបស់អ្នក
ដឹកនាំក្រុម ។ សូមរៀបចំក្រុមទៅតាមចំនួនរបស់អ្នកដឹកនាំ ។
បើរៀបចំសមាជិកក្រុមស្របទៅតាមសហគមន៍ និង ភូមិដែល
គេរស់នៅ នោះមានប្រយោជន៍ណាស់ ។

អ្នកដឹកនាំម្នាក់ៗក្នុងក្រុម ត្រូវបង្ហាត់បង្រៀនសមាជិករបស់ខ្លួន ទៅ
តាមរបៀបដែលគ្រូគង្វាលបានបង្ហាត់បង្រៀនគាត់ដែរ ។

អ្នកដឹកនាំក្រុមគួរតែជ្រើសរើសសមាជិកម្នាក់របស់ក្រុមគាត់ មក
បង្ហាត់បង្រៀនធ្វើជាអ្នកជំនួយ ។ អ្នកដឹកនាំក្រុមត្រូវដាក់កិច្ចការ
ដឹកនាំអោយអ្នកជំនួយបន្តិចម្តងៗ ។ បន្ទាប់មក អ្នកជំនួយអាច
ដឹកនាំក្រុមនោះ ឬ ចាប់ផ្តើមក្រុមផ្សេង ដែលនាំឱ្យអាចបង្កើន
ចំនួនក្រុមបន្តៗទៀតជាច្រើន ។

តើនឹងមានរឿងអ្វីកើតឡើង បើសិនជាលោកគ្រូជុនបង្រៀនពួកអ្នក
ជឿថ្មីអំពីគោលជំនឿរបស់ព្រះគម្ពីរមួយឆ្នាំ រួចទើបអោយពួកគេ
ចេញទៅផ្សាយដំណឹងល្អដល់មនុស្សឯទៀត ? ។

_____

_____

_____

បើសិនជាពួកអ្នកជឿថ្មីផ្សាយដំណឹងល្អប្រាប់សាច់ញាតិ និង មិត្ត
ភក្តិរបស់ពួកគេ ពេលពួកគេមានទឹកចិត្តរំភើប និង ពុះកញ្ជ្រោល
ដោយសារទើបនឹងមានមេត្រីភាពថ្មីជាមួយនឹងព្រះគ្រីស្ត នោះមាន
ប្រយោជន៍ណាស់ ។ ពួកអ្នកដែលចេះផ្សាយដំណឹងល្អ ពេល
ដែលពួកគេនៅជាអ្នកជឿថ្មីនៅឡើយ នឹងបន្តផ្សាយដំណឹងល្អ
រហូតពេញមួយជីវិត ។ អ្នកជឿថ្មីចាត់ទុកកិច្ចការ ដែលគេបាន
ចេះនៅក្នុងរយៈពេលប៉ុន្មានខែ ដែលគេទទួលជឿព្រះជាម្ចាស់ដំបូង
ថា សំខាន់ណាស់ ហើយគេបន្តធ្វើកិច្ចការទាំងនោះតទៅទៀត ។
បើសិនជាគ្រូគង្វាលរង់ចាំបង្រៀនពួកគេមួយរយៈពេលយូរពេក
ទើបដឹកនាំអ្នកជឿថ្មីអោយផ្សាយដំណឹងល្អ អ្នកទាំងនោះមុខជា
ខ្ជិលមិនផ្សាយដំណឹងល្អប្រាប់អ្នកឯទៀតទេ ។

តើលោកគ្រូជុនត្រូវបង្រៀនអ្វីដល់ពួកអ្នកជឿថ្មី ដែលនឹងមានភារៈកិច្ចផ្សាយដំណឹងល្អដល់អ្នកឯទៀត ? ។

គ្រូគង្វាលត្រូវបង្រៀនពួកអ្នកជឿថ្មី អោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់សំខាន់ៗទាំងប្រាំពីររបស់ព្រះយេស៊ូគ្រីស្ត ។ សេចក្តីបង្គាប់សំខាន់មួយ គឺផ្សាយដំណឹងល្អអំពីព្រះយេស៊ូប្រាប់អ្នកដទៃ ។

ការសំខាន់ គឺអ្នកជឿថ្មីត្រូវប្រតិបត្តិតាមសេចក្តីបង្គាប់ដំបូងទាំងពីរសិន បន្ទាប់មក គេនឹងប្តេជ្ញាចិត្តផ្សាយដំណឹងល្អប្រាប់អ្នកដទៃជាដាច់ខាត :

- កែប្រែចិត្តគំនិត និង ជឿ ។
- ទទួលពិធីជ្រមុជទឹក ។

បើអ្នកជឿប្រតិបត្តិតាមសេចក្តីបង្គាប់ដ៏សំខាន់ៗទាំងនេះរបស់ព្រះយេស៊ូ ដោយស្មោះត្រង់ អ្នកនោះអាចនឹងចូលរួមចែកចាយដំណឹងល្អអំពីព្រះយេស៊ូប្រាប់អ្នកដទៃ ប្រកបដោយប្រសិទ្ធិភាព ជាមួយនឹងគ្រូគង្វាល :

បណ្តុះបណ្តាលពួកអ្នកជឿ អោយមានសមត្ថភាពអាចបំពេញមុខងារបំរើ ជាអ្នកដឹកនាំក្រុមផ្សាយដំណឹងល្អ

ជ្រើសរើសពួកអ្នកជឿ ដែលជឿលើព្រះយេស៊ូជាព្រះសង្គ្រោះ និងព្រះអម្ចាស់របស់ពួកគេ ដែលបង្ហាញថា ពួកគេស្រឡាញ់ព្រះជាអម្ចាស់ និង មនុស្សឯទៀត ហើយដែលចេះយកចិត្តទុកដាក់ស្តាប់គ្រូបង្រៀន ។

អញ្ជើញពួកអ្នកទាំងនោះឱ្យហាត់រៀនជាមួយអ្នក ដើម្បីអាចបំពេញមុខងារបំរើ ជាអ្នកដឹកនាំក្រុមផ្សាយដំណឹងល្អ ។ សូមចាប់ផ្តើមបង្រៀនមនុស្សពីបីទៅប្រាំនាក់ មួយអាទិត្យម្តង ។

បង្ហាត់បង្រៀនពួកអ្នកដឹកនាំទាំងនេះ ទាំងមុខជំនាញ ទាំងសកម្មភាព ដើម្បីអោយពួកគេអាចបង្រៀនមុខជំនាញ និងសកម្មភាពទាំងនោះ បន្តដល់មនុស្សឯទៀត ។ ការបង្ហាត់បង្រៀនប្រភេទនេះអាចរួមបញ្ចូល : ការអធិស្ឋាន ការតមអាហារ ការធ្វើអោយចរិតលក្ខណៈរីកចំរើនឡើង ការទៅសួរសុខទុក្ខ ការជួយមនុស្សឯទៀត ដោយធ្វើកិច្ចការបំរើខាងពលកម្ម ការផ្សាយដំណឹងល្អ ការចែកចាយដំណឹងល្អ ដោយនិទានរឿង និង ការបង្រៀនមេរៀនអំពីដំណឹងល្អ ។ កុំគ្រាន់តែបង្រៀនខ្លឹមសារនៃមេរៀនដល់

© Project WorldReach © SEAN

៣- ផែនការសំរាប់គ្រួគង្វាល ដែលធ្វើអោយក្រុមជំនុំរីកចំរើន

- បណ្តុះបណ្តាលពួកអ្នកជឿ អោយមានសមត្ថភាពអាច បំរើកិច្ចការ ជាអ្នកដឹកនាំក្រុមផ្សាយដំណឹងល្អ ។
- រៀបចំក្រុមផ្សាយដំណឹងល្អ សំរាប់សហគមន៍ផ្សេងៗ គ្នា ។
- សមាជិកក្រុមចាប់ផ្តើម ដោយផ្សាយដំណឹងល្អប្រាប់ សាច់ញាតិ និង មិត្តភក្តិរបស់ពួកគេ ។
- ក្រៅពីផ្សាយដំណឹងល្អប្រាប់សាច់ញាតិ និង មិត្តភក្តិ សមាជិកនៃក្រុមផ្សាយដំណឹងល្អ ត្រូវប្រាប់មនុស្សដែល មិនទាន់ឮអំពីដំណឹងល្អរបស់ព្រះយេស៊ូ ។
- រៀបចំក្រុមបង្កើតសាវ័កតាមផ្ទះ ដើម្បីបង្រៀនពួកអ្នក ជឿថ្មី ។

- ស្រឡាញ់ព្រះជាម្ចាស់ និង មនុស្សឯទៀត ។
- យកព្រះបន្ទូលព្រះជាម្ចាស់ធ្វើជាអាហារខាងព្រលឹងវិញ្ញាណ ហើយអធិស្ឋានរាល់ថ្ងៃ ។
- ចូលរួមប្រជុំថ្វាយបង្គំជាមួយគ្រីស្តជនឯទៀត ។
- ថ្វាយដង្វាយ ។

ទីបំផុត អ្នកជឿទាំងអស់ត្រូវផ្សាយដំណឹងល្អដល់មនុស្សឯទៀត និង បង្កើតសាវ័ក គឺបង្រៀនពួកអ្នកជឿថ្មីអោយចេះស្តាប់បង្គាប់ ព្រះគ្រីស្ត :

- ផ្សព្វផ្សាយដំណឹងល្អ និង បង្កើតសាវ័ក ។

អ្នកត្រូវប្រើក្លូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល ទី ៧ «របៀបបង្កើតសាវ័ក ដោយប្រើមេរៀន"ការដើរតាមព្រះអម្ចាស់ យេស៊ូគ្រីស្ត " » និង ក្លូនសៀវភៅ ទី ៣០ «សេចក្តីបង្គាប់ទាំង ៧ » ដើម្បីបង្រៀនពួកអ្នកជឿថ្មីអំពីសេចក្តីបង្គាប់សំខាន់ៗរបស់ ព្រះគ្រីស្ត ។

ជំនឿលើព្រះយេស៊ូគ្រីស្ត ជីវិតវិសុទ្ធដែលជាផលផ្លែរបស់ជំនឿនេះ ក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និង ចំពោះមនុស្សឯទៀត ព្រមទាំងការស្តាប់បង្គាប់ព្រះគ្រីស្ត ជាមូលដ្ឋានសំរាប់ការផ្សាយដំណឹងល្អ និង ការបង្កើតសាវ័ក ។

បើអ្នកជឿថ្មីចេញទៅផ្សាយដំណឹងល្អប្រាប់អ្នកដទៃបណ្តើរ និងសិក្សាព្រះបន្ទូលព្រះជាម្ចាស់បណ្តើរ នោះនាំឱ្យអ្នកជឿមានកំឡាំងផ្សាយដំណឹងល្អ និង សិក្សាណាស់ ។ ការសិក្សាព្រះបន្ទូល និងការអធិស្ឋានជាប្រេងឥន្ធនៈសំរាប់ដុតភ្លើងនៃការផ្សាយដំណឹងល្អ ។

លោកគ្រូជុនត្រូវការអោយអ្នកផ្តល់យោបល់អោយគាត់ ។ សូមស្តាប់គំនិតខុសឆ្គងរបស់គាត់ :



២- ក្រុមជំនុំខ្លះរីកចំរើនឡើង ដោយសារពួកគេទាក់ទាញយកសមាជិករបស់ក្រុមជំនុំផ្សេងទៀត ។ ហេតុអ្វីបានជាការរីកចំរើនបែបនេះ មិនមែនជាការរីកចំរើនពិតប្រាកដរបស់ក្រុមជំនុំព្រះគ្រីស្ត ? ។

_____

_____

_____

_____

៣- តើនឹងមានរឿងអ្វីកើតឡើង បើសិនជាគ្រូគង្វាលធ្វើកិច្ចការឃ្វាលទាំងអស់ ធ្វើការប្រជុំថ្វាយបង្គំ និង ធ្វើការផ្សាយដំណឹងល្អ ដោយខ្លួនឯងទាំងអស់ ? ។

_____

_____

_____

_____

_____

តើមានអ្វីកើតឡើងនៅក្នុងរឿងនេះ ? ។

បើសិនជាគ្រីស្តជនផ្សាយដំណឹងល្អ ដោយដំបូងចែកចាយដំណឹងល្អរបស់ព្រះយេស៊ូប្រាប់កុមារ ឬ យុវជន នោះពួកគេច្រើនតែធ្វើអោយមនុស្សពេញវ័យមានចិត្តគំនិតប្រឆាំងនឹងដំណឹងល្អ ។ ពួកមនុស្សពេញវ័យនឹងចាត់ទុកការផ្សាយដំណឹងល្អដូចនេះ ជាការខិតខំទាក់ទាញយុវជន និង កុមារឱ្យបែរចេញពីវប្បធម៌ និង សាសនារបស់ពួកគេ ។ បើគ្រីស្តជនដឹកនាំមេគ្រួសារ និង ក្រុមគ្រួសារទាំងមូលៗឱ្យជឿលើព្រះយេស៊ូនោះ មានប្រយោជន៍ច្រើនជាង ។

១- សំរាប់ក្រុមជំនុំដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត ការផ្សាយដំណឹងល្អ មិនមែនជាកម្មវិធី « ពិសេស » ទេ ប៉ុន្តែ ជាករណីយកិច្ចប្រចាំថ្ងៃទៅវិញ ។ ហេតុអ្វីបានជាសេចក្តីនេះត្រឹមត្រូវ ? ។

នៅអាទិត្យបន្ទាប់ លោកគ្រូជុនអធិប្បាយពីរម៉ាង ។ ក្នុងចំណោមមនុស្សដែលមកចូលរួមក្នុងកម្មវិធីនេះ ភាគច្រើនជាគ្រីស្តជនរួចទៅហើយ ។ នៅពេលដែលលោកគ្រូជុនប្រកាសឱ្យដាក់ដង្វាយ ពួកអ្នកមិនទាន់ជឿនាំគ្នាដើរចេញ ។ នៅសល់មនុស្សតែមួយចំនួនតូច ដែលចាប់អារម្មណ៍លើព្រះយេស៊ូ ប៉ុន្តែ លោកគ្រូជុនមិនអាចរកផ្ទះពួកគេឃើញ ដើម្បីបន្តសួរសុខទុក្ខពួកគេទេ ។

តើលោកគ្រូជុនបានធ្វើអ្វីខុស ? ។

កម្មវិធីផ្សាយដំណឹងល្អមានអត្ថប្រយោជន៍ខ្លះ ក្នុងការផ្សាយដំណឹងល្អប្រាប់មនុស្សឯទៀត ។ ប៉ុន្តែ ការផ្សាយដំណឹងល្អតាមគ្រួសារដោយបង្កើតអោយមានទំនាក់ទំនង និង បង្ហាញសេចក្តីស្រឡាញ់ជាកិច្ចការ ដែលពួកអ្នកជឿអាចធ្វើបានគ្រប់គ្នា ហើយថែមទាំងជារបៀបផ្សាយដំណឹងល្អ ដែលមានប្រសិទ្ធិភាពផង ។

លោកគ្រូជុនត្រូវការអោយអ្នកផ្តល់យោបល់អោយគាត់ ។ សូមស្តាប់គំនិតខុសឆ្គងរបស់គាត់ :



យុវជនបានចាប់ផ្តើមមកព្រះវិហារ ដើម្បីលេងបាល់ទះ ស្តាប់រឿងរបស់ព្រះគម្ពីរ និង ច្រៀងចំរៀងអំពីព្រះយេស៊ូ ។ ប៉ុន្តែ ពួកមនុស្សពេញវ័យចាប់ផ្តើមតវ៉ាថា÷

